# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ប្រគល់វិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្ម ជូនលោកវិចិត្រករ រឿម ប៊ុនហាក់




ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំពិធីប្រគល់វិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្ម ការពារកម្មសិទ្ធបញ្ញា ជូនវិចិត្រករ រឿម ប៊ុនហាក់ សម្រាប់ការរកឃើញ វិធីសាស្ត្រនៃការគូររូបភាព ដោយប្រើប្រាស់ដែកក្បាលមាន់ ដុតឲ្យក្តៅគូរលើស្លឹកត្នោតស្ងួត ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មនាសៀលថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ នៅក្នុងសាលប្រជុំនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ថ្លែងក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានកោតសរសើរ ចំពោះទេពកោសល្យរបស់លោក រឿម ប៊ុនហាក់ ដែលជាការរកឃើញដំបូង សម្រាប់វិចិត្រករខ្មែរ ហើយក៏ជាការលើកមុខមាត់សម្រាប់ជនជាតិខ្មែរ ព្រោះគំនូរដែលលោកគូររួច មិនត្រឹមតែទទួលបានការគាំទ្រ ពីប្រជាជនខ្មែរប៉ុណ្ណោះទេ តែក៏ទទួលបានការចាប់អារម្មណ៍ និងកោតសរសើរយ៉ាងខ្លាំង ពីភ្ញៀវបរទេសផងដែរ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានបន្ថែមទៀតថា ដើម្បីឲ្យវិស័យផលិតកម្មក្នុងស្រុក អាចរីកចម្រើនទៅមុខលឿន វិស្វករ ផលិតករ វិចិត្រករ ក៏ដូចជាសិប្បករខ្មែរទាំងអស់ ត្រូវខិតខំធ្វើយ៉ាងណា

រិះរកនូវការបង្កើតថ្មី ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ដើម្បីលើកតម្កើងឲ្យផលិតកម្មក្នុងស្រុកផង និងក៏ជាមុខមាត់របស់ប្រទេសជាតិផង។ ជាងនេះទៅទៀត ឯកឧត្តមទេសរដ្ឋមន្ត្រី បានជម្រុញឲ្យ វិស្វករ ផលិតករ សិប្បករខ្មែរទាំងឡាយណា ដែលបានរកឃើញនូវការបង្កើតថ្មីនានា ត្រូវរួសរាន់យកស្នាដៃរបស់ខ្លួន មកចុះបញ្ជីដើម្បីស្នើសុំការការពារផ្នែកច្បាប់ ទៅលើអ្វីដែលជាស្នាដៃផ្ទាល់ខ្លួនរបស់ពួកគេ ដែលមិនបានលួចចម្លងពីអ្នកដទៃ។

ដោយឡែកតាមការឲ្យដឹង ពីលោកវិចិត្រករ រឿម ប៊ុនហាក់ ដែលកំឡោចរូបគំនូរលើស្លឹកត្នោត បានបញ្ជាក់ថា លោករកឃើញនៅវិធីសាស្ត្រថ្មី ក្នុងការយកកម្ដៅភ្លើងធ្យូង មកកំឡោចលើស្លឹកត្នោត ឲ្យចេញជារូបគំនូរយ៉ាងរស់រវើកនេះ តាំងពីឆ្នាំ២០០៧ មកម្ល៉េះ គឺនៅពេលដែលលោកធ្វើជាអ្នករត់តុគុយទាវឲ្យឪពុកមារបស់លោក។ នៅពេលដែលលោកប្រមូលសម្រាម នៅខាងមុខហាងគុយទាវ យកទៅដុត ដែលសម្រាមទាំងនោះ ក៏មានលាយស្លឹកត្នោតផងដែរ ដែលធ្វើឲ្យចំហេះនៃសម្រាមទាំងនោះ មានក្លិនធុយម្យ៉ាង ដែលជាក្លិននៃចំហេះស្លឹកត្នោត។

លោកបន្តថា ដោយសារតែហេតុនេះហើយ ទើបធ្វើឲ្យលោកមានការចាប់អារម្មណ៍ និងដោយសារលោកមានទេព្យកោសល្យ ផ្នែកគំនូរស្រាប់ លោកក៏បានសាកល្បង យកដែកទៅដុតឲ្យក្ដៅ ហើយរោលទៅលើស្លឹកត្នោត ដើម្បីឲ្យចេញជារូបគំនូរផ្សេងៗ។ នៅដំណាក់កាលដំបូង វាពិតជាមានការលំបាក និងទាមទាឲ្យមានការអត់ធ្មត់ជាខ្លាំង ដើម្បីអភិវឌ្ឍន៍វិធីសាស្ត្រគូរឲ្យមានភាពរលូន ដូចការយកជក់ ឬខ្មៅដៃគូរនៅលើក្រដាស ដែលលោកត្រូវប្រើពេលវេលាជាច្រើនឆ្នាំ ដើម្បីឲ្យមានភាពស្ទាត់ជំនាញដូចសព្វថ្ងៃនេះ។

គួរបញ្ជាក់ផងដែរថា វិញ្ញាបនបត្រដែល វិចិត្រករ រឿម ប៊ុនហាក់ ទទួលបានក្នុងថ្ងៃនេះ គឺជាវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មការពារកម្មសិទ្ធបញ្ញា លើវិធីសាស្ត្រគូររូបភាព ដោយប្រើប្រាស់ដែកក្បាលមាន់ដុតឲ្យក្ដៅគូរលើស្លឹកត្នោតស្ងួត។ ជាពិសេសទៅទៀតនោះ គឺ លោក រឿម ប៊ុហាក់ បានក្លាយជាជនជាតិខ្មែរដំបូងគេ ដែលទទួលបាននូវវិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្មការពារកម្មសិទ្ធបញ្ញាលើស្នាដៃបង្កើតថ្មីរបស់លោក ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។








អបអរសាទរ
ពិធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation - Religion - King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ...

# វិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្ម
## Patent Certificate

យោងតាមផ្នែកទី ៨ ជំពូកទី ២ នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ **ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** បញ្ជាក់ថា តក្កកម្មនេះ ត្រូវបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ចុះលេខ កជ/ផប្រត/00005 ការពារកម្មសិទ្ធិបញ្ញា ដែលមានសេចក្តីអត្ថាធិប្បាយលម្អិត ដូចខាងក្រោម៖

In accordance with Section 8 of Chapter 2 of the Law on Patents, Utility Model Certificates and Industrial Designs of the Kingdom of Cambodia dated 22 January 2003, the Ministry of Industry & Handicraft hereby certifies that this invention has been granted a Patent Certificate under N° KH/GP/00005, to protect intellectual property rights with the detailed description as follows:

| | |
|---|---|
| ចំណងជើងតក្កកម្ម | : វិធីសាស្ត្រគូររូបភាពដោយប្រើប្រាស់ដែកក្បាលមាន់ដុតឲ្យក្តៅគូរលើស្លឹកត្នោតស្ងួត |
| Title of invention | : **Sugar palm leaf pyrography art technology using specially shaped soldering iron** |
| លេខសំណុំលិខិតស្នើសុំ | : កជ/ប្រត/២០១៦/000៤១ |
| Application number | : KH/P/2016/00041 |
| កាលបរិច្ឆេទសុំចុះបញ្ជី | : ០៥ សីហា ២០១៦ |
| Filing date | : 05 August 2016 |
| កាលបរិច្ឆេទអាទិភាព | : គ្មាន |
| Priority date | : None |
| ឈ្មោះនិងអាសយដ្ឋានម្ចាស់ | : **រឿម ប៊ុនហាក់** ភូមិ បន្ទាយចាស់ សង្កាត់ ស្លក្រាម ក្រុង សៀមរាប ខេត្ត សៀមរាប កម្ពុជា |
| Name and address of owner | : **ROEUM BUNHAK** **Banteay Chas, Sangkat Slor Kram, Siem Reap City, Siem Reap Province , Cambodia.** |
| កាលបរិច្ឆេទនៃការផ្តល់ | : ...១៦...សីហា. ២០១៦ |
| Date of grant | : ...16...Aug... 2016 |

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦
Phnom Penh, Date ...16...Aug.... 2016

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Senior Minister, Minister of Industry & Handicraft

**ចម ប្រសិទ្ធ**


Cambodia
Angkor Wat





អបអរសាទរ
ពិធី
ប្រគល់វិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្ម
ការពារកម្មសិទ្ធិបញ្ញាលើ
CNC
BTV